# ឆ្មានៅក្នុងអក្សរសិល្ប៍ និងក្នុងវប្បធម៌ខ្មែរ

*ដោយ*

*បណ្ឌិតសភាចារ្យឃីងហុកឌី*

*ឆ្មា ជាសត្វចតុប្បាទ ដែលប្រជាជនខ្មែរ សម្គាល់ជាទូទៅថា /chma/[1]។ ក្នុងអក្សរសិល្ប៍ប្រជាប្រិយខ្លះ ជួនសម្គាល់ដោយពាក្យថា « ម៉ែវ »[2] ដោយប្រដូចនឹងសំនៀងទំនួញសម្រែកសត្វចតុប្បាទនេះ។ ផ្ទុយទៅវិញក្នុងអក្សរសិល្ប៍ទំនៀមបុរាណ ក្នុងរឿងល្បែងនានាកវីតែងហៅសម្គាល់សត្វចតុប្បាទនូវពាក្យ«ពិឡារ ឬ វិឡារ »[3]។ វាក្យស័ព្ទ ដែលសម្គាល់សត្វចតុប្បាទនេះ គឺមានចែងក្នុងសិលាចារឹកខ្មែរបុរាណ ច្មា # ឆ្មា cmā # chmā [4]។ ពាក្យនេះ*

---

[1] *ឆ្មា (ខ្មែរ) គឺសម្គាល់សត្វចតុប្បាទមួយប្រភេទ, ឆ្មារ គឺមានន័យថា «ស្តើង,តូច, ឆ្មាល់ » (នៅខេត្ត តាកែវ អ្នកភូមិ និយាយថា /chmal/ តែខ្មែរជាទូទៅ និយាយនូវសំនៀងដូចគ្នា ចំពោះពាក្យទាំង២ នេះ។* G. Cœdès, *បានឲ្យនិយមន័យពាក្យ ឆ្មារ នេះ ក្នុងសៀវភៅ Inscriptions du Cambodge*, vol. II, Hanoï, p.189, n. 6 *: chmār* « étroit », K. 470, « Inscription du Bayon ».

[2] *ក្នុងភាសាសៀមក៏ហៅសត្វចតុប្បាទនេះ ថា /mèv/ ហើយ យួន ក៏ ហៅថា /mèo/ ដែរ។*

[3] *មកពីពាក្យបាលី "ពិឡារ ឬ វិឡារ" ដែលកវីបណ្ឌិតបានប្រើក្នុងកំណាព្យ, ក្នុងរឿងល្បែង និងក្នុង រាជស័ព្ទ។*

[4] *សូមអាន* « Inscription du Phnom Ho Phnou » (Vie siècle de l’ère çaka), K. 76, ligne 7 (G. Cœdès, *Inscriptions du Cambodge*, vol.V, Paris, 1953, p. 8). Long

ទៀតសោតខ្មែរយើងប្រើសម្គាល់សត្វចតុប្បាទនេះរៀងរហូតមកដល់បច្ចុប្បន្នកាល។

នៅក្នុងសង្គមនានាក្នុងសាកលលោក « ឆ្មា » ជាសត្វចតុប្បាទនៅកំដរសំណាក់អាស្រ័យនឹង មនុស្សតាំងតែពីបុរាណកាលតៗមក។ នៅក្នុងសង្គមខ្មែរទំនៀម, សត្វចតុប្បាទនេះ មានទំនាក់ទំនង យ៉ាង ស្អិត រមួតនឹងស្ត្រី[5] នឹងគេហដ្ឋាន ហើយនិងពិធីនានាក្នុងកសិកម្មខ្មែរយើង។ ការជ្រើសរើស សត្វឆ្មាមកចិញ្ចឹម គឺខ្មែរទំនៀមតែងជ្រើសរើសតាម « លក្ខណ៍ »[6] វា បានសេចក្ដីថាគឺទៅតាម លក្ខណៈសម្គាល់ដែល មានពណ៌នា ក្នុងក្បួនតម្រាបុរាណ។

---

Seam, (« Les anthroponymes sur les inscriptions du Cambodge du Vie au XIIIe siècle », *Acte du Sud-Est continentale, vol. 2, Actes du XXIXe Congrès international des Orientalistes*, Paris, L’Asiathèque, 1976, p. 95). សូមអានបន្ថែម បណ្ឌិតសភាចារ្យ ឡុងសៀម, *វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦ - ៨)*, ភ្នំពេញ, ២០០០, ទំព័រ២២៥។

[5] « ឆ្មា » ដែលអាចនាំសិរីសួស្ដី ជ័យមង្គលដល់ម្ចាស់អ្នកចិញ្ចឹម ខ្មែរយើងហៅថា « ឆ្មាគ្រប់លក្ខណ៍ »គឺឆ្មាដែលមានសម្បុរ ៣។ វាក្យស័ព្ទ នេះយើងបានយកមកប្រើសម្គាល់ នារី នានាដែលមានលក្ខណៈសម្បត្តិល្អប្រសើរផ្ដល់សេចក្ដីសុខចម្រើនដល់គ្រួសារ ក៏ហៅ ថា « ស្ត្រីគ្រប់លក្ខណ៍ » ដែរ។

[6] លក្សណៈ (សំស្ក្រឹត), លក្ខណៈ (បាលី) មានន័យ ថា គ្រឿងសម្គាល់, គ្រឿងចំណាំ, គ្រឿងសង្កេតខ្លួនប្រាណចង្អុលឲ្យឃើញច្បាស់ថាមានភ័ព្វឬឥតភ័ព្វ, គុណសម្បត្តិ។ល។(វចនានុក្រមខ្មែរ)។

## ការនិទានផ្សេងៗទាក់ទងនឹងកំណើតឆ្មា

*នេះជារឿងនិទានមួយពីកំណើតឆ្មា[7] ដែលចេញពីលោហិតរដូវស្ត្រី៖*

*« អតីតេ ក្នុងកាលនោះមានមហាឫសីមួយអង្គនៅព្រៃភ្នំមួយឈ្មោះវុឌ្ឍីបព៌ត តាំងចម្រើមភាវនា ក្នុងទីភ្នំនោះ ជាអង្វែងឆ្នាំមកហើយ។ នៅកន្លែងនោះ មានស្រះបួនគឺទិស បូព៌ា១ ទក្សិណ១ បស្ចិម១ និង ឧត្តរ១។ ស្រះនោះមានទឹករង៉ថ្លា មានដុះឈូកក្រហមឈូកស និងបុប្ផាផងទាំងពួងជាទីសប្បាយនៃមច្ឆាគ្រប់បែប ឯមាត់ ច្រាំងក៏ជ្រាល មុខគួរឲ្យសប្បាយពេកណាស់។ ស្រះទាំងបួននៅឆ្ងាយពីអាស្រមប្រហែលមួយយោជន៍ ព្រះឥសីក៏ធ្លាប់តែទៅស្រង់ទឹកពាល់ដងផង។ មានសម័យថ្ងៃមួយ ព្រះឥសីគង់ចំរើនមេត្តាភាវនាដោយញាណឈានលោកិយ សព្វគ្រប់ឃើញថា៖ « ឱ! មានទេពធីតាមកចាប់កំណើត ក្នុងផ្កាឧប្បលដែលដុះក្នុងស្រះខាងឧត្តរ បានអាយុ ៩ថ្ងៃហើយតើ អាត្មាអញក៏ខានទៅស្រង់ទឹកឯស្រះនោះ៩ថ្ងៃហើយដែរ »។ ព្រះឥសីក៏ដាក់ស្មឹងស្មាធិ៍គិតថា « អាត្មាអញ គួរទៅយកមកចិញ្ចឹមបីបាច់ថែរក្សា*

---

[7] « *រឿងកំណើតសត្វឆ្មា* », *ប្រជុំរឿងព្រេងខ្មែរ, ទាក់ទងដោយសត្វនិងរុក្ខជាតិ, ភាគ៧, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨,ទំព័រ៣៩-៤៦។ រឿងនេះតែងឡើងវិញដោយលោកលីធាមតេង តាមលំនាំឯកសារតម្កល់នៅក្រុមជំនុំទំនៀមទម្លាប់ភ្នំពេញលេខ ២៧.០២៦ របស់ សម-នូរ* (*មុនឆ្នាំ១៩៧៥*)។ *រឿងនេះទៀតសោតសិក្សា ដោយ សាស្ត្រាចារ្យបណ្ឌិត សូឡង់ចេរី* Solange Thierry, *Le Cambodge des contes*, Paris, L'Harmattan, 1986, p. 133-140.

ចុះ » គិតហើយក៏រៀបអង្គផ្ទង់ដំណើរតម្រង់ទៅទិសឧត្តរ ដល់ស្រះហើយ ព្រះឥសីឈរសំឡឹងមើលគ្រប់ផ្កាឃើញផ្កាឧត្បលមួយធំខ្ពស់ ឃើញនាងទេវធីតាអង្គុយក្នុងផ្កានោះ ព្រះឥសីក៏ចុះទៅកាច់យកផ្កានោះមក ហើយនិមន្តត្រឡប់មកកាន់អាស្រមវិញ ចិញ្ចឹមថែរក្សា ជាសុខ សប្បាយៗ លុះដល់នាងធំ ក៏យកឈ្មោះថា **ឧត្តរបុប្ផា** លុះអាយុ១៥វស្សា លោកតាក៏ភ្នកព្រះទ័យនឹកអាណិតចៅស្រី ព្រោះពេញរូបរាងទៅហើយ នៅកំព្រាឥតគ្នីគ្នានឹងលេងប្រឡែង ឯកឯងអផ្សុកវិតក្កចិត្ត ដូច្នេះគួរតែអញយកបុប្ផាមួយទៀតមកជបឲ្យកើតជាគ្នា គ្រាន់បានជាពីរនាក់ៗ ព្រះឥសីគិតហើយឈ្វេងយល់ថា ឥឡូវបើយកផ្កាដទៃផ្សេងមកជបជាមនុស្សទៅ ឃើញថាជាជាតិផ្កាដូចគ្នា ដូច្នេះចាំយកជាតិដែលកើតពីនាងផ្ទាល់វិញៗ ឥសីគិតហើយក៏ហៅនាង **ឧត្តរបុប្ផា** មកផ្ដាំថា បើកាលណានាងធំពេញរាងហើយមានរដូវ ចូរនាងផ្ដិតសំឡីទុកឲ្យតាៗនឹងជបឲ្យបានគ្នាគ្រាន់នឹងលេងពីរនាក់ៗ នាង **ឧត្តរបុប្ផា** បានឮលោកតាមានពុទ្ធដីកាហើយ ក៏ត្រេកអរពន់ពេក លុះដល់គំរប់ពេលមានរដូវកាលហើយ នាងក៏យកទៅថ្វាយលោកតាតាមបណ្ដាំៗ

លោកតាប្រាប់នាងថាៈ « អើចៅ! ថ្ងៃស្អែកនេះចៅនឹងបានគ្នាជាពីរនាក់ គ្រាន់និយាយលេងសោះអផ្សុកហើយៗ » វេលាយប់នោះ នាងដេកពុំលក់សោះ ទន្ទឹងចាំតែព្រឹកឆាប់ នឹងអាលបានគ្នាជាពីរនាក់ៗ លុះព្រឹកឡើង លោកតាក៏បិទទ្វារកុដិ តាំងវាយក្អែន

សង្រួមភាវនាវេទមន្តជបបានថ្នាមួយសម្បុរបី អំពីលោហិតរដូវដែលនាងផ្តិតឲ្យទៅនោះ។ រួចស្រេចហើយឥសីហៅនាងឧត្តរបុច្ឆា មក ហើយលើកថ្នាហុចមកឲ្យនាង ប្រាប់នាងថា « នេះជាគ្នារបស់នាងហើយ សត្វនេះឈ្មោះថា ឆាម៉ា »។ សត្វនេះចេះនិយាយគួរសមជាមួយនាង នាងក៏ទទួលយកមកថែរក្សាដោយសេចក្តីស្រឡាញ់ពេញចិត្ត ទុកដូចជាកូនឬប្អូន ឱបដល់ឱរាបីយកទៅក្នុងបន្ទប់ ទៅណាមកណា តែងយកទៅតាមនិយាយគ្នាបីដូចមនុស្សដូច្នោះ។ លុះដល់អាយុនាងបាន១៧ឆ្នាំ ទើបឥសីដាក់កំណត់ច្បាប់មាត្រា ឲ្យនាងកុំឲ្យភាន់ច្រឡំ សំរាប់ជាច្បាប់តទៅកូនចៅស្រីៗឯក្រោយទៀត គឺថាជាតិស្រីទាំងអម្បាលម៉ានមិនត្រូវទាត់សត្វឆាម៉ានេះនឹងជើង ឬ វាយនឹងអម្បោស ឬ មួយនឹងត្របុតត្រីអាំង។ កុំថាតែទាត់ជាក់ សូម្បីតែដើរកន្ទងក៏មិនបានដែរ ត្បិតសត្វនេះកើតឡើងដោយលក្ខណ៍ស្រី។ បើស្រីណាទាត់ជាក់ ឬដើរកន្ទងសត្វនេះហៅថាស្រីហីនលក្ខណ៍ ហើយបើប្រព្រឹត្តច្រើនដងទៅ ហៅថាស្រីខាតលក្ខណ៍។ តមកប្រមាណ១៤ខែ សត្វឆាម៉ាក៏កើតកូនឈ្មោលមួយឡើងទៀត។ គឺជាឆាម៉ាទាំងពីរនេះហើយជាកំណើតឆ្មាទាំង អស់។

និយាយពីស្តេចមួយអង្គនាមសោទត្ត ព្រះរាជបិតាលើករាជ្យសម្បត្តិឲ្យកូននេះសោយរាជ្យ ពីព្រះជន្មបាន២១ព្រះវស្សានៅនគរឈ្មោះតក្កសីលា។ ស្តេចថ្មីនោះសោយរាជ្យឡើងសោយរាជ្យពុំមានមហេសីទេ ត្រអាលក្រសាលតែនឹងស្រីស្នំបរិពារ។ លុះ

អង្វែងទៅ ស្ដេចទ្រង់ផ្ទំវេលាយប់មួយ លោកនឹកក្នុកព្រះទ័យចង់ចេញទៅលេងព្រៃ។ លុះភ្លឺស្វាងកាលណា ស្ដេចក៏ចេញចុងព្រះពាង ឲ្យនាម៉ឺនមុខមន្ត្រីគាល់ដូចសព្វដង។ លុះជួបមន្ត្រីអស់ហើយ ស្ដេចក៏មានព្រះបន្ទូលប្រាប់ថា « យើងចង់ទៅលេងព្រៃនៅថ្ងៃស្អែក ចូររៀបចំពលថ្មើរជើងនិងសេះដំរី រៀបស្បៀងអាហារក្រយាស្ងោយគ្រាន់គ្រប់គ្នាកុំឲ្យខ្វះ។ » នាម៉ឺនទទួលព្រះរាជឱង្ការកាលណា ក៏រៀបគ្រប់ប្រដាប់ឥតមានខ្វះ ពលថ្មើរជើង ពលសេះដំរី រួចស្រេចហើយ ក៏ចូលក្រាបបង្គំទូលស្ដេចទ្រង់ជ្រាប។ លុះដល់កំណត់ថ្ងៃហើយ វេលាព្រឹកស្ដេចក៏យាងចេញទៅដោយសេនាទាហានហែតាម លុះបានបួនថ្ងៃក៏បានទៅដល់ព្រៃហេមវន ស្ដេចក៏មានព្រះឱង្ការឲ្យបោះព្រះពន្លាមួយនៅទីនោះ។ អស់ទាំងសេនាទាហានក៏ ធ្វើជំរំ គ្រប់ៗ តាមមុខរបស់ខ្លួនស្រេចហើយស្ដេចមានបន្ទូលបើកអំណាចឲ្យអស់សេនាលេងល្បែង ភ្លេងច្រៀងរាំតាមចិត្តសប្បាយក្នុងព្រៃនោះ។ នៅពេលយប់នោះ ស្ដេចក៏ចូលផ្ទំក្នុងព្រះពន្លាជ័យ លុះអធ្រាត្រស្ងាត់ ឮសូរតែមាត់បក្សី គ្រប់ភាសាយំ មុខគួរឲ្យស្រងេះស្រងោច ក្នុងព្រះទ័យមមៃនឹកគិតគ្រប់សព្វ។ លុះភ្លឺស្វាងព្រះសុរិយាកាលណា ស្ដេចក៏មានព្រះរាជឱង្ការបង្គាប់ទៅរាជអមាត្យឲ្យរៀបទីន័ងអស្សតរថ្វាយ ព្រះអង្គនឹងត្រេចមើលព្រៃ កំសាន្តព្រះទ័យ ជាមួយនឹងរាជអមាត្យ ពីរនាក់បី នឹងស្ដេច។ រួចហើយចេញទៅល្ងាចត្រឡប់មកព្រះពន្លាជ័យវិញ។ គ្រប់បីថ្ងៃនៅវេលាព្រឹក១ ស្ដេចក៏បរទីន័ងទៅដល់ស្រះកំណើត

នាង**ឧត្តរបុប្ផា** ទ្រង់ទតទៅឃើញទឹកដំរកថ្លា ឃើញបុប្ផានិងមច្ឆា ជាតិគ្រប់បែប ហែបហែលជ្រួលច្រវាត់មុខគួរឲ្យទ្រង់សព្វព្រះទ័យ នឹងចុះស្រង់ៗ ទើបស្ដេចមានបន្ទូលទៅអមាត្យទាំង២ថា «យើងង្ងូតទឹកស្រះនេះឲ្យត្រជាក់កាយសប្បាយចិត្តសិនសឹមបន្តដំណើរទៅ» ទើបឈប់លែងពាជីឲ្យស៊ីស្មៅ រួចផ្លាស់ព្រះពស្ត្រស្រង់ទឹកព្រមទាំងរាជអមាត្យ ទឹកក៏ត្រជាក់ធ្វើឲ្យមានកម្លាំងមែនៗ រួចហើយឡើងផ្លាស់ព្រះពស្ត្រស្រេច ស្ដេចក៏យាងទតតាមឆ្នេរស្រះទៅ ឃើញមានផ្លូវទក់ៗ ព្រះអង្គនឹកថា « យី! ព្រៃនេះជាសមសាន្តឋានស្ងាត់ណាស់ម្ដេចឡើយក៏មានផ្លូវមនុស្សដើរដូច្នេះ»ៗ រួចស្ដេចក៏បន្ទូលទៅនឹងរាជអមាត្យថា « នៅចាំយើងទីនេះចុះ យើងដើរទៅមើលត្រង់នោះបន្តិចៗ» ស្ដេចយាងតាមផ្លូវព្រះឥសីនោះទៅៗ បន្តិចបានក្រឡេកឃើញអាស្រម ស្ដេចនឹកក្នុងព្រះទ័យថា «រោងនេះជារោងអី? ជាផ្ទះព្រានព្រៃទេ ឬ អ្វី?» ព្រះអង្គចេះតែយាងចូលទៅ ឯព្រះឥសីកំពុងឆាន់ នាង **ឧត្តរបុប្ផា** អង្គុយគាល់លោកតាៗ លុះស្ដេចយាងដល់ទទួលនាងនោះក្រឡេកឃើញ នាងក៏ស្ទុះចូលក្នុងបន្ទប់ៗ ព្រះឥសីសួរទៅនាងថា « ម្ដេចក៏ស្ទុះរត់ចូលក្នុង? » នាងនិយាយតិចៗ ទូលឥសីថា « មានមនុស្សពីណាដើរចូលមក »ៗ ព្រះឥសីក៏បែរព្រះភក្ត្រទតយល់ដូចនាងទូលមែនៗ ឯព្រះរាជា លុះយល់ច្បាស់ដូច្នោះហើយក៏ចូលទៅថ្វាយបង្គំព្រះឥសី, ឥសីក៏ឈប់ឆាន់ សួរទៅស្ដេចថា « នែចៅមកពីណា បានជាចូលមកដល់ទីនេះ? » ទើបស្ដេចទូលឥសីថា « ខ្ញុំព្រះករុណាមកពី

នគរតក្កសីលា» ឥសីឈ្វេងយល់មួយរំពេចថា នេះជាស្ដេច ទើបព្រះអង្គសួរទៅទៀតថា « ស្ដេចចៅ មកទីនេះប្រាថ្នាអ្វី? » ព្រះបាទសោទត្ត ទូលឥសីតាមដំណើរ ឯឥសីឈ្វេងយល់ថា ស្ដេចអង្គនេះត្រូវជាគូនឹងនាង**ឧត្តរបុប្ផា** លោកក៏ហៅចៅស្រីឲ្យចេញមកថ្វាយបង្គំព្រះរាជា។ ហេតុតែនាងជាស្រីមានលក្ខណ៍ ក៏ចេញមកថ្វាយបង្គំតាមពុទ្ធដីកា។ ព្រះអង្គក្រឡេកយល់នាង នាងក៏យល់ព្រះភក្ត្រព្រះអង្គច្បាស់ ហើយចាប់ចិត្តទៅវិញទៅមក ទើបព្រះឥសីមានព្រះពុទ្ធដីកាថា « ស្ដេចចៅនេះហើយដែលជាគូនឹងនាងតាំងតែអំពីអតីតជាតិមកម៉្លេះ »។ គ្រានោះឥសី សួររកសេនារេហ៍ពល ព្រះបាទសោទត្តក៏ទូលថា « ព្រះអង្គយកតែអមាត្យពីរនាក់មកតាមទេ ឥឡូវឲ្យឈប់ចាំនៅឯមាត់ស្រះខាងទិសឧត្តរឯណោះ ត្រង់ថាខ្ញុំព្រះករុណាត្រូវជាគូស្រករនឹងនាងនេះ ក៏ស្រេចតែលោកតា បើសព្វព្រះទ័យយ៉ាងណា ខ្ញុំព្រះករុណាទទួលធ្វើតាមទាំងអស់»។ ឥសីបញ្ជាទៅវិញថា «បើដូច្នេះ សូមស្ដេចចៅថយទៅរៀបចំសង់រោងបីល្វែង ហើយរកផ្កាឲ្យបាន៧ពណ៌ យកមកចងផ្ដុំជាបីបាច់ ទុកឲ្យតាទៅប្រសិទ្ធីពរជ័យឲ្យបានគ្នាជាប្ដីប្រពន្ធសុខសប្បាយតទៅ»។

ស្ដេចស្ដាប់ព្រះពុទ្ធដីកាហើយ ក៏រួសរាន់ថ្វាយបង្គំលា យាងមកដល់ទីកន្ទែងស្រះដែលឲ្យអមាត្យចាំ ហើយបបួលអមាត្យត្រឡប់ទៅកាន់ពន្ធាជ័យវិញ ដល់ហើយបញ្ជានាម៉ឺនសេនាគ្រប់ក្រុម ឲ្យរៀបចំសង់រោងបីល្វែង តាមបង្គាប់ឥសី។ បានរួចស្រេច

ក៏ឲ្យក្បួនទ័ពព្រមទាំងក្មេងតូរ្យតន្រ្តីពិរោះល្វើងល្វើយ ទៅដង្ហែនាង **ឧត្តរបុប្ផា** ពីអាស្រមឥសី និមន្តទាំងព្រះឥសីឡើងគង់ព្រះវរសលៀងដង្ហែមកកាន់ព្រះពន្លា។ ដល់ហើយព្រះតាបសតាំងសូត្រទិព្យមន្ត ព្រះឥសីក៏បាចផ្កាទាំង៧ពណ៌នោះថ្វាយពរជ័យដល់គូស្រករថ្មី។ បីថ្ងៃតមក ទើបព្រះអង្គនិងនាងជាយាថ្វាយបង្គំលាលោកតា នាងក៏ស្រក់ទឹកភ្នែកនឹកអាល័យលោកតា ព្រោះតាំងពីកើតមក ពុំដែលបែកទៅណាសោះ ឥឡូវមិនដឹងជាកាលណានឹងបានមកថ្វាយបង្គំវិញ។

គ្រានោះឥសីផ្ដាំថា៖ បើនាងទៅដល់ប្រាសាទហើយមុននឹងឡើងទៅលើប្រាសាទ នាងត្រូវឱបសត្វឆ្មា ហើយដើរព័ទ្ធប្រទក្សិណប្រាសាទ៣ជុំ រួចសឹមឡើងទៅនៅក្នុងប្រាសាទនោះទើបនាងបានសុខ មានសិរីសួស្តី។ នាងស្ដាប់សព្វគ្រប់ហើយ ក៏លាចេញទៅ លុះទៅដល់ព្រះរាជវាំងហើយ មុននឹងចូលព្រះរាជដំណាក់ព្រះនាងបានធ្វើតាមបណ្ដាំឥសីឥតឲ្យខ្លង ក៏បានប្រកបដោយសេចក្ដីសុខចំរើនរហូតទៅ។

ទំនងជាដោយសាររឿងនេះទេដឹង បានជាខ្មែរយើងមានទំនៀមមួយ ក្នុងពេលធ្វើពិធីឡើងផ្ទះថ្មី គឺគេនិយមឱបឆ្មាមួយ ហើយដើរប្រទក្សិណផ្ទះបីជុំ ហើយស្រេចទើបគេឡើងនៅ»។

គោលរឿងដែលមានប្រធានបទសត្វឆ្មាក្នុងអត្ថបទអក្សរសិល្ប៍ទំនៀម គឺមាននៅក្នុងរឿងល្បែងដែលមានចំណងជើងថា

**ចម្ប៉ាថោង ឬ ចំប៉ាថោង**[8]។ តួអង្គឯកជាស្ត្រីនាម នាងចម្ប៉ាថោង មានសត្វឆ្មាញីមួយជាកិលៀងជំនិត ឈ្មោះ**ឆាងវិឡារ**[9] ហើយសត្វឆ្មានេះ ជាចន្ទល់និងជាឬសកែវក្នុងការពិពណ៌នានិទានសាច់រឿងទាំងមូល។ សេចក្តីសង្ខេបរឿងនេះមានពណ៌នានៅខាងក្រោមស្រាប់។

« ថ្ងៃមួយ**ព្រះឆាងចម្ប៉ាថោង** ជារាជបុត្រីមហាក្សត្រ បានរើស ពងក្រពើមួយ។ ព្រះបិតាព្រះនាងបានឲ្យព្រះនាងបោះចោលពងក្រពើនេះ តែនាងពុំបានធ្វើតាមព្រះបន្ទូលបិតា បានយកពងនោះទៅដាក់ទីដែលមានកំដៅ បានញាស់កូនក្រពើចេញមក។ ព្រះនាងយកទៅចិញ្ចឹមក្នុងពាងទឹក រួចយកទៅលែងក្នុងស្រះ។ ពីរបីឆ្នាំមក ក្រពើនោះកាន់តែធំៗឡើង ស្រះទឹកនោះទៅជាតូចចង្អៀត ស្តេចបញ្ជាឲ្យអមាត្យយកទៅលែងក្នុងសមុទ្រ។

---

[8] រឿង**ចម្ប៉ាថោង**នេះមានជាសាស្ត្រាស្លឹករឹតនិពន្ធជាកំណាព្យកាព្យឃ្លោង រក្សាតម្កល់ទុកនៅបណ្ណាល័យសាលាបារាំងចុងបូព៌ាក្រុងប៉ារីស ចុះលេខ៧៩ មាន៣ខ្សែ។ សំណេរដែលចម្លងនៅសតវត្សទី១៩ ជាឯកសារលើក្រដាសរបស់លោក អែមូនីយេ៉ (Aymonier) រក្សានៅបណ្ណាល័យសមាគមអាស៊ីក្រុងប៉ារីស ចុះលេខ B39(3)។

[9] វិឡារ ឬ ពិឡារ (បាលី)មានន័យជាខេមរភាសាថា « ឆ្មា »។ ពាក្យនេះកវីនិពន្ធយើងប្រើក្នុង អត្ថបទកំណាព្យ។

សត្វក្រពើនោះមិនសប្បាយចិត្ត បានទូលស្តេចឲ្យយកព្រះនាងចម្ប៉ាថោងឲ្យវាស៊ី បើមិនដូច្នោះទេ វានឹងស៊ីប្រជានុរាស្ត្រ នគរនេះទាំងអស់មិនខាន។ ស្តេចទ្រង់ព្រះតម្រិះថា វិបត្តិហេតុនេះកើតឡើងដោយកំហុសព្រះនាងចម្ប៉ាថោង ហើយស្តេចក៏បញ្ជាឲ្យអមាត្យនាំព្រះនាងយកទៅឲ្យក្រពើស៊ីតាមសេចក្តីស្នើរបស់សត្វនេះ។

ក្សត្រី បានចិញ្ចឹមសត្វឆ្មាញីមួយ ទន្ទឹមនឹងការចិញ្ចឹមក្រពើនោះ។ ព្រះនាងចម្ប៉ាថោងនឹងនាងឆ្មាវិឡារសោកសៅតាមផ្លូវដើរឆ្ពោះទៅកាន់សមុទ្រ។លុះទៅដល់មាត់សមុទ្រក៏យាងទៅលើស្ពានដោយមិនបានដឹងថា ព្រះឥន្ទ្របានទុកអាវុធដែក « ដើងក្អែក » សម្រាប់ ការពារព្រះកាយ។ ក្រពើវាហាមាត់ត្របាក់នាងតែអាវុធដែក« ដើងក្អែក »ដោតជាប់មាត់ក្រពើនោះហើយពង្រីកកាន់តែធំៗឡើង។ ព្រះនាងចម្ប៉ាថោងបិទភ្នែកនៅស្ងៀម ឯនាងវិឡារសប្បាយចិត្តជាខ្លាំង ស្ទុះទៅឱបម្ចាស់ក្សត្រី ដោយឃើញក្រពើឈឺចាប់ប្រកាច់ស្លាប់។ ព្រះនាងចម្ប៉ាថោងនិងនាងវិឡារ ឃើញដូច្នោះយល់ថា អស់គ្រោះថ្នាក់ហើយៗ ក៏ត្រឡប់ចូលក្នុងព្រះរាជវាំងវិញ ហើយបាន រៀបរាប់តាមដំណើរ ថ្វាយព្រះមហាក្សត្រសណ្តាប់។ ស្តេចបានបញ្ជាឲ្យនាងវិឡារ ធ្វើពិធីរាំវង់ថ្វាយព្រះ

*ឥន្ទ្រាធិរាជ ដោយព្រះអង្គបានជួយជីវិត ព្រះរាជបុត្រីឲ្យបានត្រឡប់មកព្រះរាជវាំងវិញ ដោយសុវត្ថិភាព »ៗ*[10]

*ឆ្មា បានក្លាយជាក្រឡាហោម ដែលឃើញមានក្នុងរឿងព្រេង* **ចៅក្តាំងចាយ**[11] *ជាពាក្យកាព្យ និង រឿងល្បែងជាកំណាព្យមានចំណងជើង* **ចៅក្តាំងចាយនិងម្ចាស់សត្រីសែនជិបតី**[12]*ៗ រឿងទាំងពីរ រចនាបទនិពន្ធខុសគ្នាគឺមួយតាក់តែងជាពាក្យកាព្យហើយមួយទៀតជាកំណាព្យតែសាច់រឿងជាទូទៅមានទម្រង់ប្រហាក់ប្រហែលគ្នាមានខុសតែចំណុចលំអិតប៉ុណ្ណោះៗ ខាងក្រោមនេះជាសម្រង់សង្ខេបខ្លះពីរឿងចៅក្តាំងបាយពាក្យកាព្យ៖*

*« ក្នុងអតីតកាលមានបុរសម្នាក់និងភរិយារស់នៅនានគរទេពបុរីៗលុះបានបុត្រា១អាយុ៣ឆ្នាំមាណពនិងភរិយាទទួលអនិច្ចកម្មទុកកូនប្រុសរស់នៅជាមួយជីដូនចាស់ៗ*

---

[10] *សូមអានបន្ថែម* Eveline Porée-Maspero, *Etude sur les rites agraires des Cambodgiens*, t. I, Paris/La Haye, Mouton, 1967, p.102-102.

[11] **ចៅក្តាំងចាយ**, *ពាក្យកាព្យ, ប៉ារីស, ប៉ុង នូរី, ១៩០២, ៣២ទំព័រៗ* **ចៅក្តាំងចាយ**, *ឯកសារលើក្រដាសតម្កល់រក្សាទុកនៅ បណ្ណាល័យសាលាបារាំងចុងបូព៌ា ចុះលេខ១៩២* [P.91] *ជាពាក្យកាព្យមាន ៤៤ទំព័រៗ រឿងព្រេងនេះបកប្រែដោយសាស្ត្រាចារ្យបណ្ឌិត* Solange Thierry, *De la rizière à la forêt, contes khmers*, Paris, L'Harmattan, p. 192-213.

[12] **រឿងចៅក្តាំងចាយនិងម្ចាស់សត្រីសែនជិបតី**, *ភ្នំពេញ, បណ្ណាគារភ្នំពេញ, ១៩៥៤, ១៣៤ទំព័រៗ*

កុមារនេះមិនចង់ហូបតែក្តាំងបាយហើយពេលណាដែលជីដូនវាឲ្យបាយទន់បរិភោគ,វាយំទាស៊ីតែក្តាំងបាយ។ហេតុនេះហើយបានជាគេឲ្យឈ្មោះវាថា**ចៅក្តាំងបាយ**រៀងរហូតមក។

យាយចាស់និងចៅមានជីវភាពតោកយ៉ាកណាស់។ពេលណាបានហូបពេលព្រឹកគឺខានហូបពេលល្ងាច តែបើបានហូបពេលល្ងាចអត់បានហូបពេលព្រឹកពោលគឺខ្វះព្រឹកខ្វះល្ងាច។លុះចៅក្តាំងបាយធំបន្តួរគឺអាយុបាន៧ឆ្នាំប្រកបដោយប្រាជ្ញាឆ្លាតវៃជួយជីដូនចាស់ក្នុងការចិញ្ចឹមជីវិត[...]។

នៅជិតនិគមនោះ មានសេដ្ឋីម្នាក់ចិញ្ចឹមឆ្មា១មានលក្ខណសម្បត្តិល្អប្រសើរដែលនាំឲ្យលោកសេដ្ឋីស្រឡាញ់ណាស់។តែថ្ងៃមួយ, ឆ្មានោះឃើញអ្នកបម្រើលើកធ្វើម្ហូបអាហារជូនសេដ្ឋីជាម្ចាស់វាបានស៊ីមុនសេដ្ឋី ជាហេតុនាំឲ្យសេដ្ឋីក្រោធជាខ្លាំងហើយបញ្ជាឲ្យ អ្នកបម្រើ២នាក់យកឆ្មានោះទៅបំបរបង់ចោល។អ្នកបម្រើទាំង២នេះបានជួបតាមផ្លូវចៅក្តាំងបាយត្រឡប់ពីនេសាទបានត្រី៣ព្យួរលើស្មា។ ចៅនេះបានសួរទៅថា៖

-តើយកឆ្មានេះ ទៅទីណា?

អ្នកបម្រើទាំង២ក៏ឆ្លើយទៅវិញថា៖

-យើងយកឆ្មានេះទៅបំបរបង់ចោល។

ឮដូច្នោះ ចៅក្តាំងបាយស្នើទៅថា៖

-ប្រសិនបើយកឆ្មានេះទៅបំបរបង់ចោល សុំដូរឆ្មានេះនឹងត្រី២។

អ្នកបម្រើទាំងពីរយល់ព្រមតាមសំណើដោយបានត្រី២ត្រឡប់ទៅផ្ទះវិញហើយយកទៅចម្អិនបរិភោគដោយរីករាយ...។ ថ្ងៃពីសេដ្ឋីម្នាក់ទៀតមានចិញ្ចឹមឆ្កែមួយ។ ថ្ងៃមួយអ្នកបម្រើយកស្រូវទៅហាលថ្ងៃឲ្យស្ងួតដើម្បីយកទៅបុកជាអង្ករដាំបាយធ្វើម្ហូបជូនម្ចាស់។ តែពេលនោះឆ្កែមកនោមលើស្រូវហាល ហើយសេដ្ឋីឃើញដូច្នោះក្រោធខឹងជាខ្លាំង បញ្ជាឲ្យអ្នកបម្រើយកឆ្កែនោះទៅបំបរបង់ចោល។

នៅតាមផ្លូវអ្នកបម្រើទាំងនោះបានជួបចៅក្តាំងបាយដែលត្រឡប់ពីនេសាទនៅបឹងវិញបានត្រី៣។ ចៅក្តាំងបាយបានសួរអ្នកបម្រើនោះថា៖

-តើនាំឆ្កែនេះទៅទីណា?

អ្នកបម្រើក៏ឆ្លើយវិញថា៖

-យកវាទៅបំបរបង់ចោល។

ចៅក្តាំងបាយឮដូច្នោះក៏ស្នើទៅវិញថា៖

-បើអ្នកយកឆ្កែនេះទៅបំបរបង់ចោល, សូមឲ្យមកខ្ញុំៗនឹងជូនត្រី២ទៅវិញ។

អ្នកបម្រើសេដ្ឋីក៏យល់ព្រម។ ចៅក្តាំងបាយស្រាយយកត្រី២ប្រគល់ឲ្យអ្នកបម្រើហើយក៏ យកត្រី១នៅសល់និងឆ្កែត្រឡប់ទៅផ្ទះវិញ។ អ្នកបម្រើក៏ត្រឡប់ទៅផ្ទះវិញដែរ។

ដល់ផ្ទះចៅក្តាំងបាយបានឲ្យត្រី១នៅសល់ទៅជីដូនដើម្បីចម្អិនសម្រាប់បរិភោគ។ ថ្ងៃបន្ទាប់ៗមកទៀត មានដំណើរជីវិត

បន្តៗដូចប្រក្រតី[...]។

[ថ្ងៃមួយនោះ ថៅក្តាំងបាយរើសបានពង ពីរ របស់រាជក្សត្រី កុជង្គនាគ ហើយញាស់បានកូននាគ២ គឺនាគឈ្មោល១ និងនាគញី១។ ថៅក្តាំងបាយចិញ្ចឹមបីបាច់រក្សារហូតដល់ចេះហោះហើរបានហើយបាន។ នាគនោះនាំថៅក្តាំងបាយរហូតទៅដល់បាតាលនាឋានកុជង្គនាគ។ ក្សត្រាក្សត្រីនាគទាំងពីរ ឲ្យ កែវទិព្វមកថៅក្តាំងបាយ ដែលអាចប្រាថ្នាអ្វីបានតាមចំណង់។ ក្រោយបន្តិចមក អាស្រ័យដោយកែវទិព្វ ថៅក្តាំងបាយ បានរៀបការជាមួយម្ចាស់ក្សត្រីនគរ ទេពបុរីហើយក៏បានឡើងស្នងរាជ្យ ជំនួសបិតាក្មេក។ ដោយការច្រណែននឹងស្តេចថៅក្តាំងបាយ, ស្តេចបច្ចាមិត្របញ្ជូននាយទាហានមកលួចយកកែវទិព្វ]។

ពេលនោះ ថៅក្តាំងបាយបានរត់ដោះខ្លួនរួចទៅជាមួយសត្វឆ្កែនិងឆ្មា។ ស្តេចថៅក្តាំងបាយបានហៅឆ្កែនិងឆ្មាមកជិតហើយនិយាយថា៖

-បងឆ្កែនិងបងឆ្មា សូមបងទាំងពីរជួយខ្ញុំក្នុងពេលអាសន្នអន់ក្រនេះ ដណ្តើមយក កែវទិព្វ ពីស្តេចសត្រូវមកវិញបានហើយពេលណាច្បាំងឈ្នះលើបច្ចាមិត្រ រួចបានឡើងសោយរាជ្យវិញ ខ្ញុំនឹងតែងតាំងបង១ជា ក្រឡាហោម ហើយបង១ទៀតជាយមរាជ។

ឆ្កែនិងឆ្មាឆ្លើយតបវិញថា៖

-យើងខ្ញុំចេញទៅដណ្តើមយក កែវទិព្វ តាមរាជបញ្ជា។

បន្ទាប់ពីយកបាន កែវទិព្វមកវិញ យកមកប្រគល់ឲ្យ ចៅក្តាំងបាយ ជាម្ចាស់។

ដោយបាន កែវទិព្វ មកវិញ នាំឲ្យចៅក្តាំងបាយ មានសេចក្តីក្លាហានឡើងវិញ អាចចេញដំណើរ ទៅធ្វើសឹកសង្គ្រាម ជាមួយស្តេចសត្រូវ ហើយក៏បានលើកកែវទិព្វនោះក្រវី នឹក ផ្សងអធិដ្ឋានថា៖

« ដោយតេជៈដែលសណ្ឋិតក្នុងកែវទិព្វនេះ សូមឲ្យបង្កើតបានជាវេហ៍ពលច្រើនអនេកគិនី មានសព្វាវុធគ្រប់ដៃ។ »

ចៅក្តាំងបាយ បរទ័ពទៅវាយកបង្ក្រាបទ័ពខ្មាំងគ្មានសល់ ព្រមទាំងចាប់ស្តេចបច្ចាមិត្រនោះបានផងដែរ(...)។

បន្ទាប់ពីបានជ័យជំនះនេះមក ចៅក្តាំងបាយបានកោះហៅហោរមកទស្សន៍ទាយរកថ្ងៃជាពេលាល្អដើម្បីប្រារព្ធរាជាភិសេកឡើងសោយរាជ្យជាមហាក្សត្រ ជាមួយព្រះនាងពៅជាព្រះទេពីនៅនគរ ទេពបុរី។

ស្តេច ចៅក្តាំងបាយ បានតែងតាំង ធ្នា ជាក្រឡាហោម ហើយ ក្តែ ជាយមរាជ។ ប្រជានុរាស្ត្រត្រូវហៅ **ក្រឡាហោម ម៉ា** និង ហៅ **យមរាជ កែ** តាំងពីពេលនោះរៀងមក ។

ក្នុងសត្រាល្បែង **រឿងចៅក្តាំងបាយ និង ម្ចាស់សត្រីសែនជិបតី** បានបញ្ចប់ដូចសម្រង់ខាងក្រោមនេះ៖

« សេនាបតី មន្ត្រីតូចធំ
បានមកជួបជុំ ឡើងគាល់ព្រះមហា

ក្សត្រថ្ងៃឧត្តម។
មានព្រះឱង្ការ ខ្លួនខ្ញុំនេះណា
ឡើងសោយរាជហើយ ខ្ញុំនឹកទៅដល់
ក្អែឆ្មាជាន់មុន ខ្ញុំបាននិយាយ
ឲ្យវាជួយខ្ញុំ។
ឲ្យបានសម្រេច ខ្ញុំឲ្យវាធ្វើជា
កុង្សីយ៍ទាំងពីរ ឯឆ្មានោះណា
ឲ្យធ្វើជាឧកញ៉ា ជាទីយមរាជ
ជាអ្នកឃ្លាំងច្បាប់។
ឯក្អែនោះវៃ ខ្ញុំខឹងពេកក្រៃ
ធ្វើបាបឆ្មាផង ប៉ុន្តែខ្លួនខ្ញុំ
កាន់សច្ចំហោង មិនយកទោសផង
លើកចោលលែងទៅ។
ខ្ញុំឲ្យធ្វើជា កុង្សីយ៍មួយណា
ឧកញ៉ាក្រឡាហោម ក្រោមបង្គាប់គេ
ក្អែនឹកទៅខឹង ចិត្តវាខ្នះខ្នៃ
ចង់ពៀរនឹងឆ្មា។
កើតទៅជាតិណា ឃើញគ្នាដេញខាំ
រហូតមកដល់ ហោងឥឡូវនេះ
សូមលោកអ្នកផង ប្រាជ្ញាប៉ុនប៉ង

*ចង់ពៀរនឹងគ្នា។ »*[13]

## **ការជ្រើសរើសឆ្មាចិញ្ចឹម**

*អត្ថបទបុរាណជាសាស្ត្រាស្លឹករឹត មានចំណងជើងថា* **ក្បួនទំនាយឆ្មា** *គឺជាក្បួនដែលបង្ហាញពីការជ្រើសរើសឆ្មាមកចិញ្ចឹមដោយសម្គាល់ រូបលក្ខណ ទៅតាមទំនៀមជាជំនឿនិងការចងចាំនៃប្រជាជនខ្មែរយើងជាអង្វែងមកហើយ។ នេះជាសម្រង់ក្បួនទំនាយឆ្មាដែលចម្លងសរសេរជាអក្ខរាវិរុទ្ធទំនើប*[14]*៖*

*«នេះក្បួនទំនាយឆ្មាស១កំណាត់ខ្លួនឆ្មានោះចង្រៃស្មើផ្កាយភ្លើង ទោះស ថ្លាល់ទាំងសង្ខាង ហើយមានភ្នែកក្រហម រោមវែងដូចរោមក្តាន់ ហើយត្រចៀកវែង ដូចរាជសីហ៍ ឆ្មានោះមានអនុភាពក្នុងគុហា ស្តេចស្រឡាញ់អម្ចាស់នោះ ប្រសើរប្រែកបនូវ*

---

[13] **រឿងចៅក្តាំងចាយនិងម្ចាស់សត្រីសែនជិបតី**, *ភ្នំពេញ, បណ្ណាគារភ្នំពេញ, ១៩៩៤,ទំព័រ១៣១និង១៣២។ ក្នុងរឿងព្រេងចៅក្តាំងបាយ ឆ្មា បានទៅជា ឧកញ៉ាក្រឡាហោម ហើយ ឆ្កែបានទៅជាយមរាជ។ ហេតុនេះឃើញថាមានខុសគ្នាក្នុងចំណុះលំអិតខ្លះៗ។ ឧកញ៉ាមហាមន្ត្រីចតុស្តម្ភ គឺមាន ឧកញ៉ាក្រឡាហោម, ឧកញ៉ាយមរាជ, ឧកញ៉ាចក្រី និង ឧកញ៉ាជហ្វាវាំង មានសក្តិយស ១០ហ្វូពាន់ដូចគ្នា។ សូមអានឯកសារ* **ក្រមស្រុក** *តម្កល់រក្សា នៅបណ្ណាល័យ សាលាបារាំងបូព៌ាក្រុងប៉ារីសចុះលេខបញ្ជី ៨៨។*

[14] *សូមអានច្បាប់ដើមជាសាស្ត្រាស្លឹករឹតដែលតម្កល់រក្សាទុកនៅបណ្ណាល័យជាតិប្រទេសបារាំងមាន ២សន្លឹកចារទាំងសង្ខាងមានចំណងជើងដែលរក្សាតាមអក្ខរាវិរុទ្ធដើម៖* **នែះក្បួនឩំន្នាយឆ្មារ**, *ចុះលេខ* |Indochinois123 F], Au Chhieng, *Catalogue du fonds khmer*, Paris, 1953, p. 79.

កិត្តិយស ទ្រព្យ របស់ច្រើនៗ ទោះឆ្មានោះខ្មៅ ស ដូចរាជទេពីនៅក្នុងប្រាសាទ បើអ្នកឯណាបានចិញ្ចឹមឆ្មានោះ សឹងថ្កើងរុងរឿងពេកហោង។ បើឆ្មានោះមានតម្លៃប៉ុន្មានៗ ក្តីទិញយកហោង កុំលែង ឡើយ។ ទោះខ្លួនឆ្មានោះខ្មៅ ហើយមុខមាត់ មូលលក្ខិណាឆ្មានោះនឹងឲ្យជ័យស្រីសួស្តី ឈ្មោះផ្កាយព្រឹក ច្រើនទុកផ្ទះជាពេកហោង។ ទោះឆ្មានោះខ្មៅអស់ទាំងខ្លួន ហើយមានមមីសវា ស លេចហើយ មានកន្ទុយវា ស លេចខាងស្តាំ លក្ខិណា ឆ្មានោះ ស្មើផ្កាយព្រះសុក្រ ឲ្យចិញ្ចឹមជាពេកហោង។ ទោះឆ្មានោះសម្បុរលឿង ភ្នែកខ្មៅទាំង២ លក្ខិណាឆ្មានោះ នឹងឲ្យជ័យស្រីសួស្តីអស់ទ្រព្យផងទាំងឡាយ នឹងចូលមូលមកឯងពុំលែងឡើយ។ ទោះឆ្មានោះសម្បុរដូចខ្លា ហើយមុខនោះមូលវាចង្រៃពុំជា កុំឲ្យចិញ្ចឹមឡើយ។ ទោះឆ្មានោះមានក្រយៅនៅជើងក្តី នៅឯណាៗក្តីនោះពុំជាឡើយហោង។ ទោះឆ្មានោះមានក្រយៅ នៅបាតជើងទាំង៤ក្តី លក្ខិណាឆ្មានោះទុកស្មើស្តេច មានរិទ្ធីចេស្តាអស់ព្រះស្នំក្រមការសឹងមូលមកជាសំរាមច្រើន ហើយសត្រូវទាំង៨ទិស និងមកធ្វើទោសពុំបានឡើយ។ ទោះឆ្មា ស នោះ ភ្នែក ដូចពិទូរ្យ[15] ជាកែវនោះពេជ្រហោង។ នោះឲ្យចិញ្ចឹមឆ្មានោះហោង។ នោះឲ្យចិញ្ចឹមឆ្មានោះ នឹងចម្រើន យសសក្តិ នូវទ្រព្យអម្ចាស់ សព្វថ្ងៃរៀង

[15] ពិទូរ្យ ឬ ពៃទូរ្យ (សុះ វៃទូយ៌, បា, វេទូរិយ) ពេជ្រ ភ្នែកឆ្មា។

រៀបដរាបហោង។ »[16]

ដូចមានសេចក្តីបញ្ជាក់ក្នុង តម្រាក្បួនទំនាយឆ្មានេះស្រាប់ គឺប្រសិនជាចង់បានសិរីសួស្តីដល់គ្រួសារនិងផ្ទះសម្បែងគួរជ្រើសរើស ឆ្មាឈ្មោល ឬ ញីសម្បុរ៣ ដែលមានលក្ខណៈសម្បត្តិ ដូចមានចែងប្រាប់ក្នុង តម្រាក្បួនខាងនេះ។

## ជំនឿជាជាធាក់ទងដ៏នឹងសត្វឆ្មា

ដោយឃើញនៅលើសេចក្តីបញ្ចប់រឿងព្រេងកំណើតសត្វឆ្មាខាងលើស្រាប់បញ្ជាក់ថា ឆ្មានេះមានទំនាក់ទំនងយ៉ាងស្អិតរមួតនឹងពិធីឡើងផ្ទះថ្មី ពោលគឺជាប់ទាក់ទងនឹង **ពិធីក្រុងពាលី**[17] និង ពិធីក្នុងកសិកម្មខ្មែរទំនៀម[18]។

មុននឹងឡើងមកនៅផ្ទះថ្មី ខ្មែរយើងរមែងប្រារព្ធធ្វើពិធីឡើងផ្ទះថ្មី គឺនាពេលនោះម្ចាស់ផ្ទះថ្មី កាន់ឬឱបឆ្មាជាពិសេស ឆ្មាញី សម្បុរ ៣ ដើរប្រទក្សិណ ៣ជុំ ផ្ទះថ្មីនោះ។

អ្នកស្រីបណ្ឌិត អេវឺលីនប៉ូរេម៉ាស្ពឺរូ សរសេរពន្យល់ដោយយោងលើការសង្កេតលើសង្គមជនបទខ្មែរជាច្រើនឆ្នាំបង្ហាញថា

---

[16] « *ក្បួនទំនាយឆ្មា* » នេះបានយកទៅបោះផ្សាយនៅក្នុង *ទស្សនាវដ្តីកម្ពុជសុរិយា* លេខ២, ២០១៦, ទំព័រ៦៣។

[17] *សូមអានបន្ថែមនិក្ខេបបទបណ្ឌិត អេវឺលីនប៉ូរេម៉ាស្ពឺរូ* E. Porée-Maspero, « Kroṅ Pāli et rites de la maison », *Anthropos*, n° 56 (1961), p. 179-251, 548-628, 883-929.

[18] *សូមអានបន្ថែម* Eveline Porée-Maspero, *Etude sur les rites agraires…*, p. 48, 77, 101-102, 219, 263-266, 273, 279 454, 479, 636, 652 684, 701.

ពិធីឡើងផ្ទះថ្មីនេះប្រារព្ធធ្វើឡើងនៅសឹងតែគ្រប់ជនបទនៅប្រទេសកម្ពុជាទំនៀមរវាងទសវត្សរ៍១៩៥០រហូតដល់ទសវត្សរ៍ ១៩៧៥ ដូចមានកំណត់បញ្ជាក់គាត់ខាងក្រោមនេះៈ

« នៅភូមិព្រះជាតុ, ប្រទក្សិណប្រារព្ធធ្វើឡើងដោយស្ត្រីមានគភ៌បីឆ្នា ហើយញាតិមិត្ត កាន់កញ្ចប់ផ្សេងៗ... » [19]។

« នៅគៀនស្វាយក្នុង មានអ្នកភូមិធ្វើប្រទក្សិណ ដែលនិយាយថាយកទម្លាប់ពី នគរពេជ គឺ គេយកឆ្នា សម្បុរ៣គឺជាឆ្នាគ្រប់លក្ខណ៍មកដាក់ក្នុងផ្ទះហើយ យកអំបោះចងដៃម្ចាស់ផ្ទះដោយប្រសិទ្ធីពរឲ្យបានសុខសិរីសួស្តីក្នុងផ្ទះថ្មី»។[20]

« នៅព្រែកលៀប អ្នកភូមិកាន់ហិបនិងឆ្នា១ ឧបកិច្ចហាក់ដូចជាអ្នកដំណើរមករកទីកន្លែងនៅថ្មីដែលនាំសេចក្តីសុខចម្រើន»។

« នៅ បាភ្នំ អ្នកភូមិធ្វើប្រទក្សិណផ្ទះដោយកាន់ចង្ក្រានថ្នាំង រហាត់តម្បាញ និង ឆ្នា១»។

« នៅ បាពយលិច អ្នកភូមិធ្វើពិធីប្រទក្សិណ ៣ជុំផ្ទះដោយមានស្ត្រីទ្រង់គភ៌ម្នាក់បី ឆ្នា ដើរជាមួយផងដែរ»។

«នៅ ថ្នល់ជ័យ ឆ្នា សម្បុរ៣ នាំដើរប្រទក្សិណផ្ទះថ្មី»។

«នៅសៀមរាប គេនិមន្តព្រះសង្ឃមកសូត្រមន្តមុនសម្ពោធឡើងផ្ទះថ្មី។ បើគេមានជីវភាពខ្ពស់ គេផ្តល់ឲ្យអ្នកស្រុកកំសាន្ត

---

[19] សូមអានបន្ថែម Eveline Porée-Maspero, « Kroṅ Pāli »..., p. 578.

[20] ដដែល, ទំព័រ៥៧៩។

ដោយដួលល្ខោននានាមកសម្តែង ដូចជាល្ខោនខោល ល្ខោនស្រមោលជាដើម។ គេយកជណ្ដើរមកដាក់ ទិសណាដែលនាំ សិរីសួស្ដី ដោយឥតយកចិត្តទុកដាក់ដូចបុរាណកាល ពីការហែឆ្មាមង្គលសម្បុរ៣ប្រទក្សិណទេ»។[21]

«នៅស្រុកត្រាស់ក្នុងខេត្តតាកែវ គឺមាន ឆ្មាសម្បុរ៣, ស្រីគ្រប់លក្ខណ៍, ស្រីក្រមុំព្រហ្មចារីយពីរនាក់និងញាតិមិត្តកាន់គីតម្បាញ, ថ្ម១, ដូង១,កាំបិត១, ទូ១, ហិប១... ហែប្រទក្សិណ ៣ជុំផ្ទះថ្មី»។[22]

«នៅស្រុកព្រៃក្របាស ក្នុងខេត្តតាកែវ អ្នកហែប្រទក្សិណមានកាន់ប្រអប់ស្លាម្លូ, កន្ទេល, ខ្នើយ, ឆ្មា, ស្រូវ និងបាយ។ នៅស្រុកព្រៃក្របាសដដែលនេះ គេឃើញនាពេលហែប្រទក្សិណ អ្នកដើរមុខ ទូលឆ្មាសម្បុរ៣លើក្បាលដែលជា ឆ្មា គ្រប់លក្ខណ៍»។[23]

«ឆ្មា គ្រប់លក្ខណ៍ ជាឆ្មាដែលមានសម្បុរ៣ គឺអាចជាឆ្មាសម្បុរខ្មៅ ជើង៤ស ឬ ឆ្មាសម្បុរ ស ជើង៤ខ្មៅ» ។[24]

តាមជំនឿខ្មែរទំនៀម យល់ថាកាលនៅក្នុងគេហដ្ឋានមានមនុស្សស្លាប់ ម្ចាស់ផ្ទះត្រូវចាប់ឃាំងឆ្មាទុកមួយរយៈសិន ចៀសវាងកុំឲ្យសត្វឆ្មានេះកន្លងសាកសព ជាហេតុនាំឲ្យសពក្រោក

---

[21] ដដែល, ទំព័រ៥៨១។

[22] ដដែល, ទំព័រ៥៨៥។

[23] ដដែល, ទំព័រ៥៨៦។

[24] ដដែល, ទំព័រ៥៨៩។

អង្ក័យ[25]មួយស្របក់ ហើយវិញ្ញាណសពនោះក្លាយទៅ បិសាចកាចសាហាវ ដោយ ខ្មែរទំនៀមហៅថា « ខ្មោច ឆ្មាកន្ទង »។

ឆ្មាសម្បុរពញជាឆ្មាគ្រប់លក្ខណ៍មានទំនាក់ទំនងនឹងជំនឿស្ត្រី គ្រប់លក្ខណ៍ដែលនាំសេចក្តីសុខចម្រើនសុភមង្គលដល់ផ្ទះសម្បែងនិងគ្រួសារទាំងអស់។[26]

ក្នុងពិធីផ្សេងៗដែលកសិករខ្មែរយើងប្រារព្ធធ្វើ នាពេលចប់ខែប្រាំង គឺ ពិធីល្បែងហែនាងម៉ែវ ដើម្បីឲ្យមានភ្លៀងធ្លាក់បរិបូណ៌ គ្រប់គ្រាន់ពេលរដូវវស្សាភ្ជួររាស់។[27] នៅភូមិស្វូទ្រនិគម

---

[25] នេះជាជំនឿមានបង្ហាញក្នុង ឯកសារទំនៀមទម្លាប់លេខ ៩៦.០២៦៖ បើមានឆ្មាញីផើមកន្ទងសពៗនេះងើបឡើងដូចមនុស្សរស់១ស្របក់ហើយធ្លាក់ចុះវិញមួយរំពេច ឬ ក៏បណ្តាលនាំឲ្យព្រួ សម្រែកថ្ងូរ។ សូមអានបន្ថែម E. Porée-Maspero, « Kroń Pāli et rites de la maison », *Anthropos*, n° 56 (1961), ទំព័រ ៥៨៩ កំណត់១៦០។ ជំនឿនេះមាននៅប្រទេសយៀកណាមដែរ។

[26] សូមអានបន្ថែមអត្ថបទស្រាវជ្រាវ ឃីងហុកឌី Khing Hoc Dy, « Notes sur le thème de la femme « marquée de signe » dans la littérature khmère populaire », *Cahiers de l’Asie du Sud-Est*, n°2, 1978, p 15-43.។កាលនៅពីកុមារបានឮពាក្យទំនៀមនៅភូមិកំពង់ចិន ស្រុកស្ទោងក្នុងខេត្តកំពង់ធំពោលថា ឆ្មាអាចនាំ សិរីសួស្តីដល់ម្ចាស់ផ្ទះថ្មី លុះណាតែម្ចាស់ផ្ទះថ្មីនោះ ចៀសវាង៖«កាំបិតដងដូងអន្ទងពង្រ ប្រពន្ធដោះញ  គោក្រយៅក្រឡិច អំពិលឯត្បូង អន្ទង់ឯលិចមិនដឹងធ្វើម្តេច ខ្ញុំជាឆ្មា»។ បានសេចក្តីថាជា វត្ថុប្រើប្រាស ស្ត្រី សត្វពាហណៈ ដំណាំ ប្រភពទឹក ត្រូវចៀសវាងដូចពោលខាងលើនេះ ទើបឆ្មាអាចជួយនាំសិរីសួស្តីឲ្យម្ចាស់ផ្ទះថ្មីបាន។

[27] ទំនៀមទម្លាប់មានប្រារព្ធនៅប្រទេសសៀមដែរ សូមអានបន្ថែម E. Porée Maspero, *Etude sur les rites agraires*…, p. 273-274.

រលួស ក្នុងខេត្តសៀមរាប ព្រះគ្រូ ឯកញឹម បានពណ៌នាពី **ល្បែងហែណាងម៉ែវ**[28]ដូច សេចក្តីបញ្ជាក់ពិស្តារទាំងមូលចុះក្នុងទំព័រឧបសម្ព័ន្ធស្រាប់។

ជាសារុបសេចក្តីមក ឆ្មា នេះមានតួនាទីសំខាន់ណាស់ក្នុងពិធីឡើងផ្ទះថ្មី។ ខ្មែរយើងរើសរក ឆ្មាញីដែលមានសម្បុរ៣ ព្រោះសត្វចតុប្បាទនេះមានកំណើតទាក់ទងនឹងស្ត្រីភេទ ដោយមានកំណើតពីឈាមរដូវស្ត្រី ដូចមានបង្ហាញក្នុងរឿងព្រេងស្តីពីកំណើតសត្វឆ្មា។ ឆ្មានេះទៀតសោត ជួយ ទេពធីតាសម្រេបសម្រួលឲ្យនាងអាចរស់នៅសុខសាន្តជាមួយពិភពមនុស្សលោកនិងជាមួយស្វាមីជាមនុស្ស។ ទាំងនេះបានសេចក្តីថា ឆ្មានេះជាមិត្តដ៏ស្មោះស្ម័គ្រគួរជាទីស្រឡាញ់នាំឲ្យនាងមកនៅទឹកន្លែងថ្មីបានសុខស្រួលមិនភ័យខ្លាចដោយគ្មានឧបស័គ្គលំបាក។

---

[28] ឯកសារក្រុមជំនុំទំនៀមទម្លាប់ចុះលេខ ២២.០០៦តម្កល់រក្សានៅពុទ្ធសាសនបណ្ឌិត្យរហូតដល់ឆ្នាំ១៩៧៥។ ពិធីល្បែងហែនាងម៉ែវ នេះ នៅឃើញមានរហូតមកដល់ឆ្នាំ១៩៩៣ដូចមានការពណ៌នាដោយ ហ្សង់ព្យែរទីបូដាត, Jean-Pierre Thibaudat ក្នុងសារពត៌មាន *Libération*, 4-2-1993 : « A l’autre bout du Cambodge dans la province de Siemreap, le village de Kan Trak, connu pour pratiquer la danse *trott* (qui n’est pas sans rappeler l’épisode du cerf dans le *Reamker*), possède aussi une troupe tout aussi « amateur » et ancestrale que celle de Vat Svay Andet, qui pratique le *neang meo*, une danse et un chant où hommes et femmes se mêlaient mais qui aujourd’hui aux hommes. « *Le neang meo* fait venir la pluie », dit le vieux maître Phing Nhoung. Cette danse va de maison en maison avec un chat tenu en cage que chaque habitant est tenu d’asperger. Le chat n’aimant pas l’eau, on compte sur lui comme intermédiaire pour plaider la fin de son supplice auprès des *kru*. A Vat Svay Andet, village de la région de Phnom Penh, on vit au rythme du riz, de la pluie et du *« lokhon khol »*, le théâtre masqué. Tradition ancestrale que ni l’histoire ni le tourisme n’ont encore détruite ».

*ឆ្មានេះជាសត្វតំណាងការរីងស្ងួត។ ដោយហេតុនេះហើយ ដើម្បីឲ្យបានភ្លៀងធ្លាក់គ្រប់គ្រាន់ ខ្មែរយើងប្រារព្ធធ្វើល្បែងហែនាងម៉េវ។*

## ឧបសម្ព័ន្ធ

*ល្បែងហែនាងម៉េវ*

*សេចក្ដីឆ្លើយឆ្លងរបស់លោកគ្រូ ឯកញឹម*

*វិនយធម្មគណ វត្តធម្មិស្សរារាម*

*ឃុំ ស្រុកសូទ្រនិគម*

*សៀមរាប, ១៨ ខែ៨ ឆ្នាំ១៩៤៩*

*ឯកសារថតចេញពី ក្រុមជំនុំទំនៀមទម្លាប់តម្កល់នៅពុទ្ធសាសនបណ្ឌិត្យ មុនឆ្នាំ១៩៧៥។*

១២_០៦.

# ភ្នំនាងកង្រី

ក្រុមស្ដីយកតាមសំនួរ ភ្នំនាងកង្រី ចុះថ្ងៃ៣១ខែកក្កដា ១៩៨៩. កំពង់ភ្នំនាងកង្រី បានស្ដាប់ប្រជាជនចាស់ៗក្នុងស្រុក នេះជាច្រើនគ្នាដែលបានមានមនុស្សឈ្មោះ សាង ទិម សាងទីវង ឃុំត្រពាំង ឃុំស៊ាវ ឃុំខ្លះជាដើម ។ គេប្រាប់ថា : ភ្នំនេះប្រៀបដូចទៅនឹងភ្នំត្រដែង ដែលជាអ្នកស្រុកយ៉ាង ពី ភ្នំនាងកង្រី គេយកឈ្មោះមកដាក់ក្នុងស្រុក ដូចជា ... (តាមគេប្រាប់ថា ... នោះដែរ) ។ ... ក្នុងភ្នំនេះ ... នៅក្នុង ... ដែលគេនាំគ្នាលេង ... ដែលចាស់ជាងគេ ជា ... នោះគឺ :

ក- ស្លាកទំនួរមួយ មានមនុស្សម្នាក់កាន់ស្លាកនេះកាយដើរ ដែលទៅលេងផ្ទះគេ.

ខ- ដីឥដ្ឋមួយ មានមនុស្សម្នាក់ កាន់ប៉ុននេះ ធ្វើដើរដែល ទៅផ្ទះគេ.

គ- ត្រដោកមួយ មានមនុស្សម្នាក់ កាន់កុមនេះដើរដែល ទៅលេងផ្ទះគេ.

ឃ- ចង្អេរពងមាន់ មានមនុស្សម្នាក់ កាន់កន្ត្រកដើរដែល ទៅលេងផ្ទះគេ.

ង- កន្ទេលមួយបត់ដើម មានមនុស្សម្នាក់បត់ដាក់ កាន់ដើរដែលទៅលេងផ្ទះគេ ។.

ច- ស្បែកក្នុងភ្នំ ... មានមនុស្សដែរ ដាក់ដែលដែល ។

ក្រោយយូរៗមក ទើបមានឃើញបន្តែម ឈើ-ក្រប ការផ្ទះខ្លះ មាតស្ពាន-ក្រពាត ... ដំនួលខ្លះ មាត់ទន្លេខ្លះក៏មាន ។

បន្ទាប់ក៏ប្រាប់ដែលដាក់ក្នុងភ្នំ ឃើញនៅដាក់ក្នុងភ្នំដែលដែលនៅវិញ ។ ហើយទុកច្រៀងដែលគេនោះច្រៀងថា :

" ឪ ! នាងកង្រីអើយ ខ្លួនកូនកែ ១ ខ្ញុំឆ្ងាយ ... ខ្ញុំប្អូន ១ ណាមបុណ្យ ... កង្រី ខ្ញុំ ... នៅ " ។ ... ច្រៀងហើយ បន្ទាប់មកថា : " ឪ ! កង្រីអើយ ...

រួចហៅខ្ទើន ខណៈពុំមុន ក្រពើវែខ្មៅ ហៅខ្ចប់ក្លួ
ហៅក្ដួកទៅ"។ ហើយពាក្យដែលកសិករស្ដីអោយក្រពើ
នោះថា: ចេះចេះស្ទើរមិនមាន យកតាឡើងតួត ឲ្យក្លែងកាលពី
ចេះចេះស្ទើរមិនមាន លោកតា(១)ក្រពើមក។ ខ្លះថា: ចេះចេះស្ទើរ
ម៉ា ចេញចូលក្រពើមក ក្ដុះក្លាយគេមកឡើតថា: "ត្រី!
ជំពីងហើយចេះស្ទើរម៉ា ក្បូនឲ្យចេញបណ្ដោយក្រពើមក"។
ខ្លះទៀតថា: ត្រី! ជំពីង។ហើយ ប្រាប់ចេះស្ទើរម៉ា ក្បូនឲ្យ
ទេវតា អ្នកតា បណ្ដោយក្រពើមក។ នៅវេលាដែលពក្រពើ
ឡើងទៅយកហើយរាប់ក្រពើទៅមុខស្រុកគេនោះ ក៏មាន
មានគ្នាជាមួយប្រជា-ប្រាំនាក់ក៏មាន ក្រពើនិយាយថា: "
"ការស្លាប់ក្លាយហើយ ទៅប្រាប់ប្រពន្ធ ផ្ញើកូនតូច។ ដាំ
ក្អកបាយក្រពើ" ហើយបន្ទាប់មក ក្លាយ។ក្រពើមកក្លួ។
ពេលក្រពើរលត់ឈ្មោះ អាក្រពើ កំណាចក្រពើដើម
ហើយក្លាយមកហៅថាក្រពើពេលពេញក្រពើ។ ពីនេះ
ដែលក្រពើបង្ហាញប្រវត្តិតម្រៀត(២)។ ខ្លះថា "អាខ្មៅចេញ
អាចៅចាស់ក្ដូក ក្ដូកកាន់ដែលដែល" ក៏មាន ។ល។
ទៅស្រុកទំនួរ មានពេលរាល់ដីដែលនេះ នៅក្នុងខេត្តកំពង់
ពងក្រពើឈ្មោះ។ ហើយទឹកក្រពើសំរាប់ក្រពើ
អស់ហើយ ក្រពើនៅតែពាក្យក្បៀមឯង។
អ្នកស្រី-ទី២ថ្ងៃ ថា: "ត្រីត្រកួន ត្រូវក្លួបបាត់
ពេលដែលក្ដៀមនេះពីក្នុង ក៏ពេលមុននេះចំនួនណាស់
ហើយកាលនោះ ស្រុកនេះតាមក្រពើ ក្រពើស្រុកត្រពើរអស់
ក៏ពួកគេ។ ចេញបាត់ក្រពើ ក្រពើនេះ កាលពេល
នោះ មានគ្នាចំនួន ១៥នាក់ទៅ៤០នាក់ មានក្ដាររ១
ត្រីទំនួរ១ ជ្រាក១ ចង្កៀងពោធិ១ កញ្ចែចរដើម ស្លាកក្នុង
ត្រី១ អ្នកកាំបិ-២នាក់ ដែលស្ពានដើរក្រពើគប់។ខ្លះ
ក្រពើក្ដាមដើម ហើយហៅពេលក្រពើស្រុះត្រួតណា អ្នកស្ទាត់
ទីនោះ គេគូចទាចយាស់ទឹកមកពេលី អ្នកកាំបិ-២នាក់ខ្លះ
ហាស់ទឹកទៅពេលីក្នុងទៅក្នុងត្រូវព្រៃនោះឯង តាមពាក្យគេ
ថាប្រ ។ នេះរហ័សហើយទឹកយកំដីដៃទៅ ក្នុងលំត្រីដូច
ចេញ ក្ដៅពិបាកយកទៅគ្នាបណ្ដោយទឹកក្រពើត្រូវក្លួកមក"។

(១) ទីក្រុងវាលដីដែលនេះ ដែលមានពាក់ព័ន្ធដោយអ្នកតានោះ ដូន
ខ្ញុំទៅស្រុកត្រីកល មានចំណោះតែត្រីកណា ដែលជឿអ្នកតាសារពេទ
ហើយមានអ្នកតាពូទឹកទឹង ។

២៧-០០៧.

ក៏កើតជាប់ពូជមក ។

បើតាមឃរាល់ជា: មនុស្សសាវ់ដើម ច្រើនប្រកាន់ជឿថា សត្វ
ខាន់, ៣ ទាំងនេះគេច្រើនយកធ្វើយញ្ញសល រឺក៏ខ្លួបឃើញមក
ស្រីយ ។ គេធ្វើតាំងពីក្នុងគាំពាររម្ពុល ខាន់ខាន់មួយគូ១មួយ
គូ សាដើម បុក្នុងឡើងបេមត់ខ្លួង ។ ខានគេយកខាន់ឡើង សាក់
ក្នុងឡើងបសារដើម បុ កំពង់ពីដាឡេច ពីរបានទៀង ឡើងស្លុះថ្មីក៏
តែងឃើញអ្នកស្រុកកៅស្រុក៖ ខានយកក្បាល ខាន់ ៣ ជុំសាដើម
ជាឡើងក្រឹបាក់ថ្មីលោះសង ។ បើតុកសាឃរាល់យ៉ាងនេះក៏ដោយ
គូរតុកជាសារខ្លួបស្រុកនោះមួយបាន ទៅពេលលោងពីឆ្នាំ
នេះ គេលេងតែតពីចស្ងើពីរ លោងក្នុងកំណត់ថ្ងៃរាប លោងថ្មី
ក៏មាន លោងឃបក៏មាន ។ លុះបានឡើងឆ្លាក់គិបគាន់ដើបគេ
លោបលោង បើគ្មានបានគ្រឹកឡើងខ្លួនមកលេ ស្រុកលាលអ្នក
ស្រុកនោះគេនាំគ្នាលោងយាំងតទៅទៀត ។

ស្ដែងលោងពីឆ្នាំនាំរាំពីរនេះរាប តាមការជឿ
ស្វាគៅថា គ្មានធ្វើពីប្រកក់ប្រព័ន្ធ ស្លុតឥ ដម្លុ បន្ទាប
ពីស្រីសៀវភៅ គឺគេនាំគ្នាលាបឡើងម៉ូ.តិតម្លង ។

បន្ថែម: ក្នុងឆ្នាំនេះតុកគេឡើងថា "តាងប៉ើទៅហើយ តាងពីម៉ឺ១១ន
ទឹកពុល្យ តាងពីហ១ឡ ហើ ក្នុមទឹកតាក់ស្លាប តាហើយឡើង
មក ដើងឡើងហើ តាហើយឡើងមក ។ គាប់ស្លុនត្រូវធ្វើ
នោះឡើង មកពីមាន ជំនួនមួយ ម្ដងទៀត ៕

ចុះថ្ងៃឃលា គន្ធសាលាហាក់តាំងណេត

១៨-៤-១៩៩៩. នៅខេត្ត

ឡើបបាប.

គំនូរពណ៌លើក្រដាសស្ដីពី**កណ្ឌជូជក**ទាញស្រង់ចេញពីកណ្ឌទី៥នៃរឿង
**មហាវេស្សន្តរជាតក**,ផ្សាយដោយសាលាបារាំងចុងបូព៌ា,រវាងឆ្នាំ១៩៣០
មានចំណងជើងជាភាសាខ្មែរនិងជាភាសាលាវ។ ឆ្នាំអង្កុយក្នុងផ្ទះក្បែរមាត់
បង្អួច។ នៅក្រៅផ្ទះនិងក្រោមផ្ទះមានមាន់ ឆ្កែពាំត្របុតត្រីអាំង ចង្ក្រាន
និង ត្បាល់បុក។



នេះជាឆ្មា ដែលមានសម្បុរ៣ គឺ ជាឆ្មា »គ្រប់លក្ខណ៍» ដែលនាំសិរីសួស្តីដល់ម្ចាស់អ្នកចិញ្ចឹមនិងគេហដ្ឋាន។





ឆ្មានានាដែលចិញ្ចឹមនៅជប៉ុន (ប្រភពហ្វេសប៊ុក, ២០១៧)




គំនូរពណ៌ទំនើបស្តីពីរឿងល្បែង ព្រះនាងចំប៉ាថោង និង ក្រពើ
(ប្រភព ហ្វេសប៊ុក, គ្មាននាមសិល្បករ)។